ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់ព្រឹទ្ធសភា

# ប្រចាំខែមិថុនា ឆ្នាំ២០១៤

នៅក្នុងខែមិថុនា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅៈ

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បានៈ**

-បានដឹកនាំគណប្រតិភូព្រឹទ្ធសភា អញ្ជើញទៅបំពេញការងារ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានចុះហត្ថលេខាលើលិខិតថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៧៨ យាងចូល៧៩ព្រះវស្សា

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ ចំនួន១០ច្បាប់ និងចុះហត្ថលេខាលើលិខិតផ្សេងៗ ចំនួន២០លិខិត ។

**១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បានៈ**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-បានទទួលឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនការ និងសម្តែងការគួរសម

-អញ្ជើញចុះការងារមូលដ្ឋានចំនួន០៥លើក នៅរាជធានីភ្នំពេញ និងខេត្ត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ១៧៥ច្បាប់ ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាប្បានៈ**

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

- ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៨ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក ដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៣ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ នៅក្នុងរបៀបវារៈនៃសម័យប្រជុំលើកទី៥ព្រឹទ្ធសភា នីតិកាលទី៣ ។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា នៅក្នុងរបៀបវារៈនៃសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ។

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅក្នុងរៀបវារៈ នៃសម័យប្រជុំលើកទី៥ព្រឹទ្ធសភា នីតិកាលទី៣ ។

៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៥ ព្រឹទ្ធសភានីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គចំនួន០៣លើក ដើម្បី៖**

ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

១. ការអនុម័តយល់ព្រមលើពិធីសារ នៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ

២.ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

៣.ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពីគយ

៤.ការអនុម័តយល់ព្រមលើកិច្ចព្រមលើការសុំចូលរួមជាភាគីហត្ថលេខី របស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ

៥.ការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស៊ីធីលុមអេសអេ សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងសហប្រតិបត្តិការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈ នៅរាជធានីភ្នំពេញ

៦-ការរៀបចំអង្គតុលាការ

៧-លក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា

៨-ការរៀបចំការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៩-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ព្រឹទ្ធសភា នីតិកាលទី៣។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែមិថុនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម ៖

**៤.១ មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៨

**៤.២ មុខងារតំណាង**

-ទទួលពាក្យបណ្តឹងចំនួន០២ករណី និងបានទទួលលិខិតឆ្លើយតបការដោះស្រាយពាក្យបណ្តឹងពីក្រសួងយុត្តិធម៌ចំនួន០២ករណី

-ប្រជុំស្តីពីការត្រៀមលក្ខណៈរៀបចំសិក្ខាសាលាអបអរសាទរខួបលើកទី៦៦ ទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ឆ្នាំ២០១៤ ក្រោមប្រធានបទ "ការប្រើប្រាស់សិទ្ធិ និងច្បាប់"

-ប្រជុំស្តីពីបទបញ្ញត្តិគ្រប់គ្រងបុគ្គលិក និងហិរញ្ញវត្ថុសម្រាប់អគ្គលេខាធិការដ្ឋានសភាតំបន់អាស៊ី

-ប្រជុំស្តីពី "ការកសាង និងអនុវត្តគោលនយោបាយគ្រឿងស្រវឹងប្រកបដោយប្រសិទ្ធិភាព"

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ស្តីពី គម្រោងរៀបចំវេទិកា នៅខេត្តប៉ៃលិន

-ប្រជុំសមាជិកតំបន់ស្តីពី "ការលុបបំបាត់អំពើហិង្សាប្រឆាំងស្ត្រី"

-បទបង្ហាញស្តីពី "ការសិក្សាប្រៀបធៀបបញ្ហានានា នៃដំណើរការបោះឆ្នោតនៅប្រទេសបារាំង កូរ៉េខាងត្បូង ហ្វីលីពីន និងឥណ្ឌូនេស៊ី"

-បទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី និងការកិច្ចរបស់ព្រឹទ្ធសភា " ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាសហគមន៍មកពីខេត្តកំពង់ធំ

-វេទិកាថ្នាក់ស្រុកដើម្បីស្វែងយល់ស្តីពី "គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និង យេនឌ័រ" នៅខេត្តស្ទឹងត្រែង

-ចូលរួមសិក្ខាសាលាស្តីពី "ការអនុវត្តអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់"

-ទទួលជួបពិភាក្សាការងារជាមួយក្រុមត្រួតពិនិត្យ (PPR) ដឹកនាំដោយលោក Alexander Beetz ប្រធានគម្រោងសវនកម្មកំពូលអាស៊ាន (ASEANSAI Project)

-ទទួលជួបពិភាក្សាការងារជាមួយលោក **ដារ៉ារិទ្ធ គឹមយាត** នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា (PIC) និងមន្ត្រីស្តីពីគម្រោងសាកល្បង Pilot Project នៃការិយាល័យទទួលពាក្យបណ្តឹងតាមបណ្តាខេត្ត ដែលគ្រោងសាកល្បង នៅខេត្តក្រចេះ

-ទទួលជួបជាមួយលោក Daniel Heilmann ទីប្រឹក្សាច្បាប់ជាន់ខ្ពស់អាល្លឺម៉ង់ប្រចាំព្រឹទ្ធសភា និងលោក Ali-AL-Nasani នាយករងអង្គការហេនរេចបូល ស្ទីហ្វទង់កម្ពុជា ស្តីពី ការរៀបចំវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ដល់ក្រុមប្រឹក្សាសង្កាត់ ជាស្ត្រី ក្នុងរាជធានីភ្នំពេញ

-ជួបពិភាក្សាការងារជាមួយសហគមន៍កាតូលីកដឹកនាំដោយលោក **ប៉ា ជី** ជនជាតិឥណ្ឌា និងលោក **គី កេ** ជនជាតិស្វីស និងលោកនាយកអង្គការការីតាសកម្ពុជា ស្តីពីអំណោយសប្បុរសជនគាំទ្រទៅលើប្រជាពលរដ្ឋដែលមាតុភូមិនិវត្តន៍ពីប្រទេសថៃ នៅសហគមន៍កាតូលីក ខេត្តបាត់បង

-ជួបពិភាក្សាការងារជាមួយលោក **ហ្គោតូ ហ៊ុមីអុ** លេខាទី១ នៃស្ថានទូតជប៉ុន

-ជួបសំណេះសំណាលជាមួយឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងឯកឧត្តមអភិបាលរងខេត្តបន្ទាយមានជ័យ និងលោកអភិបាលក្រុងប៉ោយប៉ែត ព្រមទាំងលោកនាយកអង្គការការីតាសកម្ពុជា អគ្គមេបញ្ជាការភូមិភាគទី៥ ក្រុងប៉ោយប៉ែត ស្តីពីស្ថានភាពពលករមាតុភូមិនិវត្តន៍ប្រទេសថៃវិញ នៅច្រកទ្វារអន្តរជាតិក្រុងប៉ោយប៉ែត

-អនុញ្ញាតឲ្យលោក Benny Shiao ប្រធានក្រុមហ៊ុន Masterex មកពីប្រទេសចិន ចូលជួបសម្តែងការគួរសម និងពិភាក្សា ដើម្បីរកឱកាសមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ៤២លើក ដើម្បីសំណេះសំណាល ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយ

ភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន ១៦លើក ។

**៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **ឈិត គីមយាត** បានអញ្ជើញប្រជុំត្រីភាគីបូក (Troika-Plus) ក្នុងក្របខ័ណ្ឌសភាអាស៊ី (APA) នៅទីក្រុងអ៊ីស្លាមម៉ាបាត នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ,ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព ក្នុងក្របខ័ណ្ឌសភាអាស៊ី (APA) នៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី និងចូលរួមកិច្ចប្រជុំ AIPA Caucus លើកទី៦ នៅប្រទេសប្រ៊ុយណេ ។

-ឯកឧត្តម ស៊ឹម កា បានអញ្ជើញទៅគោរពវិញ្ញាណក្ខន្ធឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំមួយចំនួនទៀត នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ នៅសាធារណរដ្ឋប្រជាមានិតឡាវ ។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ